**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១២.០៥៤/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧

# បញ្ជីបោះឆ្នោតដែលធ្វើបច្ចុប្បន្នភាពរួច បានបញ្ជូនទៅសាលាឃុំ សង្កាត់ ដើម្បីឱ្យស្មៀនធ្វើការផ្ទៀងផ្ទាត់

នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧ គ.ជ.ប បានប្រកាសផ្សាយនៅក្នុងសន្និសីទសារព័ត៌មានមួយអំពីការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតដែលធ្វើបច្ចុប្បន្នភាពរួចដោយស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ។

ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក គ.ជ.ប និងជាប្រធានដឹកនាំសន្និសីទបានមានប្រសាសន៍ថា គិតត្រឹមថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ មជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប បានធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតរួចចំនួន ១៧ ខេត្ត ក្រុង ហើយក៏បានបញ្ជូននូវបញ្ជីបោះឆ្នោតទាំងនេះទៅ ១៧ ខេត្ត ក្រុង ដើម្បីឱ្យស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ជួយផ្ទៀងផ្ទាត់ឡើងវិញជាមួយ និងបញ្ជីបោះឆ្នោតដំបូងដែលពួកគាត់បានរក្សាទុកមួយច្បាប់ នៅសាលាឃុំ សង្កាត់ នោះ ។ ឯកឧត្តមបានបញ្ជាក់ថា ក្រោយពីស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ បានពិនិត្យ និងផ្ទៀងផ្ទាត់រួចរាល់ហើយ ពួកគាត់ និងបញ្ជូនបញ្ជីបោះឆ្នោតនេះ មកមជ្ឈមណ្ឌលកុំព្យូទ័រម្តងទៀត ដើម្បីធ្វើការកែតំរូវ និងរៀបចំដាក់ជូន គ.ជ.ប ផ្តល់សុពលភាព ។ បញ្ជីបោះឆ្នោតនេះនឹងផ្តល់សុពលភាព និងប្រកាសជាបញ្ជីបោះឆ្នោតផ្លូវការនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា តាមលទ្ធផលបណ្តោះអាសន្ននៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតរួច មានអ្នកបោះឆ្នោតចំនួន ៨.១៣២.០៦៣ នាក់ និងការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ ២០០៨ មានប្រមាណ ១៥.២៥៥ ការិយាល័យ ។ ឯកឧត្តមបានមានប្រសាសន៍ថា កន្លងមកការពិនិត្យផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោត គ.ជ.ប បានឱ្យតែឃុំ សង្កាត់ មួយចំនួនប៉ុណ្ណោះជួយពិនិត្យផ្ទៀងផ្ទាត់ ។ ប៉ុន្តែដោយសារឆ្នាំនេះជាឆ្នាំរៀបចំការបោះឆ្នោត ដូចនេះ គ.ជ.ប បានបញ្ជូនបញ្ជីបោះឆ្នោតនេះទៅទូទាំង១៦២១ ឃុំ សង្កាត់ ដើម្បីឱ្យស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ជួយពិនិត្យផ្ទៀងផ្ទាត់ជៀសវាងខុសអក្ខរាវិរុទ្ធ ឬទិន្នន័យអ្នកបោះឆ្នោត ។ ឯកឧត្តមបានបញ្ជាក់ថា ការផ្ទៀងផ្ទាត់នេះ មិនធ្វើការផ្ទៀងផ្ទាត់ដោយឱ្យប្រជាពលរដ្ឋមកមើលទេ គឺស្មៀនឃុំ សង្កាត់ ធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីបោះឆ្នោតដំបូងដែលរក្សាទុកនៅសាលាឃុំ សង្កាត់ ប៉ុណ្ណោះ។